- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពី ការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួល អគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ស្តីពី នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការផ្តល់តាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

ប្រការ ១ : ត្រូវបានដាក់ឱ្យប្រើប្រាស់គំរូសៀវភៅបន្ទុកសម្រាប់ធ្វើអាជីវកម្មឡូត៍នេសាទទឹកសាបដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២ : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់ សារុន

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត

"<u>ដើម្បីជូនជ្រាបជាព័ត៌មាន</u>"

- ដូចប្រការ ៣ "<u>ដើម្បីអនុវត្ត</u>"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ

រដ្ឋបាលជលផល

លេខ..............................ជផ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០
ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅបន្ទុកនៃឡូត៍នេសាទ

សៀវភៅបន្ទុក

ឡូត៍នេសាទ .... **លេខ**.................... **រាជធានី/ខេត្ត** ....

សម្រាប់ធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ ២០ .... – **២០** ....

និង រដូវនេសាទឆ្នាំ ២០ .... – **២០** ....

ឈ្មោះអ្នកទទួលសិទ្ធិកាន់កាប់ : ....

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
រដ្ឋបាលជលផល

សៀវភៅបន្ទុក

ឡូត៍នេសាទ .... **លេខ** .... **រាជធានី/ខេត្ត** ....

សម្រាប់ដាក់ឱ្យធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ ២០ ....- ២០ .... និងឆ្នាំ ២០ ....- ២០ ....

ប្រការ ១ : អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ តាមសេចក្តីសម្រេចលេខ .... សសរ.កសក ចុះថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង់ថ្លៃឈ្នួលឡូត៍នេសាទជូនរដ្ឋចំនួន...នៅរតនាគាររាជធានី ខេត្តសាមី។ ថ្លៃឈ្នួលនេះជាលទ្ធផលនៃការដេញថ្លៃនៅថ្ងៃទី .... ខែ .... ឆ្នាំ ២០ ......។

ប្រការ ២ : មុនពេលធ្វើអាជីវកម្ម អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទពីរដ្ឋបាលជលផលថ្នាក់កណ្តាល។

ប្រការ ៣ : ការបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទត្រូវបានកំណត់ជា .... លើក ក្នុងមួយរដូវនេសាទ ទៅតាមរយៈពេលនៃការធ្វើអាជីវកម្មនេសាទ និងតាមប្រភេទនៃឡូត៍នេសាទនីមួយៗ :

<u>រដូវទី ១</u> :

លើកទី ១ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

លើកទី ២ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

លើកទី ៣ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

<u>រដូវទី ២</u> :

លើកទី ១ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

លើកទី ២ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

លើកទី ៣ : ថ្ងៃទី .... ខែ .... ឆ្នាំ ២០ .... ចំនួន .... រៀល

ការកំណត់ចំនួនប្រាក់ដែលត្រូវបង់នៅចុងរដូវនេសាទទី ២ ត្រូវស្មើនឹងចំនួនប្រាក់កក់ធានាស្ថាពរ ហើយត្រូវបង្វែរប្រាក់កក់ធានាស្ថាពរនេះ សម្រាប់បង់បង្គ្រប់ថ្លៃឈ្នួលឡូត៍នេសាទតែម្តង។

ក្នុងករណីការបង់ប្រាក់មានការយឺតយ៉ាវចាប់ពីមួយខែឡើងទៅ ត្រូវពិន័យក្នុងមួយថ្ងៃ 0.4% នៃប្រាក់ដែលបង់មិនទាន់នោះ។ បើលើសពី ២ ខែឡើងទៅ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ឯឡូត៍នេសាទត្រូវដកហូត ហើយប្រាក់ធានាស្ថាពរក៏ត្រូវរឹបអូសតាមផ្លូវច្បាប់ដែរ។

ស៊ី

ប្រការ ៤: អ្នកដេញថ្លៃបាន ត្រូវមានកាតព្វកិច្ចបង់ពន្ធដារជូនអង្គការពន្ធមូលដ្ឋាននូវ :

- ពន្ធប៉ាតង់
- អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញ ក្នុងអត្រារួម ៥% នៃថ្លៃដេញបាន ដោយបង់ជាចំណែកៗ តាមចំនួនលើក និងពេលវេលាដូចមានកំណត់ក្នុងប្រការ ៣ ខាងលើ ។

ប្រការ ៥: អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវ :

១- ថែរក្សា និងការពារព្រៃលិចទឹកនៅក្នុងឡូត៍នេសាទ ។

២- ដាំព្រៃលិចទឹកបន្ថែមនៅកន្លែងសមស្រប ដែលកំណត់ដោយរដ្ឋបាលជលផលមានសមត្ថកិច្ច ។

៣- រៀបចំផ្លូវភ្លើងការពារព្រៃលិចទឹកនៅក្នុងឡូត៍នេសាទតាមការណែនាំរបស់រដ្ឋបាលជលផល ។

៤- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទនៅក្នុងឡូត៍នេសាទ ដោយសហការជាមួយសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ។

៥- រៀបចំឱ្យមានកន្លែងភ្ញាស់ត្រី កន្លែងអភិរក្សត្រីមេពូជ និងលែងកូនត្រីចំនួន ....ក្បាល នៅក្នុងឡូត៍នេសាទ ។ ដោយឡែក ចំពោះឡូត៍នេសាទដែលមិនអាចរៀបចំកន្លែងភ្ញាស់ត្រី ឬកន្លែងអភិរក្សត្រីមេពូជបាន ត្រូវរក្សាទុកត្រីមេពូជចំនួន .... ដើម្បីលែងក្នុងដែននេសាទ ។

៦- អនុវត្តតាមខ្លឹមសារដែលបានចែងក្នុងសៀវភៅបន្ទុក លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

៧- លែងទៅក្នុងដែននេសាទវិញនូវប្រភេទមច្ឆជាតិកំពុងរងគ្រោះថ្នាក់ ។

ប្រការ ៦: អ្នកដែលបានទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនអាចយកឡូត៍នេសាទទាំងមូល ឬផ្នែកណាមួយនៃឡូត៍នេសាទដែលបានទទួលសិទ្ធិកាន់កាប់ ទៅជួលឱ្យអ្នកដទៃឡើយ ។ ក្នុងករណីមានការរំលោភបទប្បញ្ញត្តិនេះ ត្រូវនិរាករណ៍សិទ្ធិនៃការកាន់កាប់ឡូត៍នេសាទនោះ ។

ប្រការ ៧: អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទគ្មានសិទ្ធិទាមទារឱ្យរដ្ឋសងការខូចខាត ឬសុំបន្ថយប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ ដែលបណ្តាលមកពីគ្រោះធម្មជាតិ ឬករណីប្រធានសក្តិផ្សេងៗឡើយ ។

ប្រការ ៨: ទីកន្លែងសម្រាប់ធ្វើអាជីវកម្មនេសាទ ត្រូវបានកំណត់នៅក្នុងបរិវេណព្រំប្រទល់នៃនាទីឡូត៍នេសាទ លើកលែងតែកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ និងកន្លែងអភិរក្ស ។

កន្លែងដែលទុកសម្រាប់ប្រជាពលរដ្ឋនៅក្នុងឡូត៍នេសាទ ត្រូវបានកំណត់ដូចខាងក្រោម :

- ទី ១ : .... ស្ថិតនៅ ....
- ទី ២ : .... ស្ថិតនៅ ....
- ទី ៣ : .... ស្ថិតនៅ ....

- ទី ៤ : ....ស្ថិតនៅ..................................
- ទី ៥ : ....ស្ថិតនៅ ....
- ទី ៦ : ....ស្ថិតនៅ ....
- ទី ៧ : ....ស្ថិតនៅ ....
- ទី ៨ : ....ស្ថិតនៅ ....
- ទី ៩ : ....ស្ថិតនៅ ....
- ទី ១០ : ....ស្ថិតនៅ ....

កន្លែងអភិរក្ស ត្រូវបានកំណត់ដូចខាងក្រោម :

- ទី ១ : ....ស្ថិតនៅ ....
- ទី ២ : ....ស្ថិតនៅ ....
- ទី ៣ : ....ស្ថិតនៅ ....

ព្រំប្រទល់នៃនាទីឡូតិ៍នេសាទ កន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ និងកន្លែងអភិរក្ស ត្រូវបានកំណត់យកតាមផែនទី ដែលមានភ្ជាប់មកជាមួយ ។

ចំពោះឡូត៍ជាយ ត្រូវដាក់ឱ្យចំទីតាំងសម្រាប់ធ្វើអាជីវកម្មនេសាទ ដូចបានកំណត់ក្នុងផែនទីដែលមានភ្ជាប់មកជាមួយ ។

ប្រការ ៩: មុនពេលធ្វើអាជីវកម្មនេសាទ អ្នកទទួលសិទ្ធិកាន់កាប់ឡូតិ៍នេសាទត្រូវ :

- បោះតម្រុយតាមបង្គោលព្រំប្រទល់នៃនាទីឡូតិ៍នេសាទ និងកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ ហើយដាក់សញ្ញាសំគាល់នៅចុងបង្គោល ។
- ធ្វើស្លាកសញ្ញាសំគាល់ បោះបង្គោល និងមានមធ្យោបាយសម្រាប់ដំណើរការបោះបង្គោលឡូតិ៍នេសាទ ។
- ថែរក្សា និងជួសជុលឡើងវិញនូវបង្គោលព្រំប្រទល់ឡូតិ៍នេសាទដែលមានរួចហើយ ។

ការបោះតម្រុយនៅតាមបង្គោលព្រំប្រទល់ឡូតិ៍នេសាទ ត្រូវមានការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមផែនទីឡូតិ៍នេសាទពីគណៈកម្មការបោះបង្គោលព្រំប្រទល់ឡូតិ៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម :

១- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង	ជាប្រធាន
២- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង	ជាអនុប្រធាន
៣- អភិបាលនៃគណៈអភិបាលក្រុងខណ្ឌ ឬស្រុកដែលឡូតិ៍នេសាទនៅជាប់ ឬតំណាង	ជាអនុប្រធាន
៤- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង	ជាសមាជិកអចិន្ត្រៃយ៍
៥- មេឃុំ ឬចៅសង្កាត់ដែលឡូតិ៍នេសាទនៅជាប់ ឬតំណាង	ជាសមាជិក
៦- ប្រធានភូមិដែលឡូតិ៍នេសាទនៅជាប់ ឬតំណាង	ជាសមាជិក

៧- ប្រធានគណៈកម្មការសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

គណៈកម្មការបោះបង្គោលព្រំប្រទល់ឡូត៍នេសាទ ត្រូវធ្វើកំណត់ហេតុនៃការបោះបង្គោលដោយមានអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទចុះហត្ថលេខាឯកភាព ។ កំណត់ហេតុនេះ ត្រូវតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌ ឬខណ្ឌរដ្ឋបាលជលផលសាមី អធិការដ្ឋានរដ្ឋបាលជលផលសាមី រដ្ឋបាលជលផលថ្នាក់កណ្តាល និងសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ហើយត្រូវបិទផ្សាយជាសាធារណៈ ។

កំណត់ហេតុខាងលើត្រូវបញ្ជាក់ :

១- និយាមកាទីតាំងបង្គោលនីមួយៗ ដោយបញ្ជាក់បន្ថែមពីមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ និងសញ្ញាសំគាល់ ។

២- ចម្ងាយពីបង្គោលនីមួយៗ ទៅចំណុចភូមិសាស្ត្រសំខាន់ៗ ។

ក្នុងករណីមិនឯកភាពគ្នាក្នុងការបោះបង្គោល ត្រូវបង្កើតគណៈកម្មការត្រួតពិនិត្យការបោះព្រំប្រទល់ឡូត៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម :

១- ប្រធានរដ្ឋបាលជលផល ឬតំណាង ជាប្រធាន

២- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង ជាអនុប្រធាន

៣- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង ជាអនុប្រធាន

៤- អភិបាលនៃគណៈអភិបាលក្រុង ខណ្ឌ ឬស្រុកដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាអនុប្រធាន

៥- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង ជាសមាជិកអចិន្ត្រៃយ៍

៦- មេឃុំ ឬចៅសង្កាត់ដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

៧- ប្រធានភូមិដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

៨- ប្រធានគណៈកម្មការសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

គណៈកម្មការខាងលើនេះ ត្រូវពិនិត្យផ្ទៀងផ្ទាត់តាមផែនទីឡូត៍នេសាទ និងសម្រេចឱ្យបោះបង្គោលតែម្តង ។ ក្នុងករណីនេះ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មការ ហើយត្រូវចុះហត្ថលេខាឯកភាពលើកំណត់ហេតុ ។

ចំពោះឡូត៍ដាយ មុនពេលធ្វើអាជីវកម្មនេសាទ ក៏ត្រូវមានគណៈកម្មការចូលរួមផ្ទៀងផ្ទាត់កំណត់ទីតាំងដាក់ដាយតាមផែនទីឡូត៍នេសាទ ដែលមានសមាសភាពដូចគណៈកម្មការបោះបង្គោលឡូត៍នេសាទខាងលើ ។ ក្នុងករណីមិនឯកភាព ត្រូវបង្កើតគណៈកម្មការ និងអនុវត្តតាមនីតិវិធី ដូចខាងលើដែរ ។

ប្រការ ១០: ក- រយៈពេលធ្វើអាជីវកម្មនេសាទចាប់ផ្តើមពីថ្ងៃទី .... ខែ .... ឆ្នាំ .... ដល់ថ្ងៃទី .... ខែ .... ឆ្នាំ .... ។

ខ- ទីតាំង ប្រភេទ និងទំហំឧបករណ៍នេសាទ ពេលវេលាចាប់ផ្តើម និងបញ្ចប់ការធ្វើអាជីវកម្មនេសាទ និងពេលវេលាដែលត្រូវរុះរើទីតាំងនេសាទ ត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

ប្រការ ១១: រយៈពេលបើកនេសាទសម្រាប់ធ្វើអាជីវកម្មក្នុងឡូត៍នេសាទគ្រប់ប្រភេទ ដោយរាប់ក្នុងមួយឆ្នាំ ពេលចាប់ពីថ្ងៃទី ០១ ខែ តុលា ដល់ថ្ងៃទី ០១ ខែ មិថុនា តាមស្ថានភាពភូមិសាស្ត្រនៃឡូត៍នេសាទនីមួយៗ លើកលែងតែឡូត៍ដាយត្រីលិញ។

មុនរដូវបិទនេសាទយ៉ាងតិច ១៥ ថ្ងៃ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវធ្វើលិខិតស្នើសុំសន្និធិផលនេសាទក្នុងឡូត៍នេសាទនៅខណ្ឌរដ្ឋបាលជលផលសាមី។

ប្រការ ១២ : ហាមឃាត់ដាច់ខាតចំពោះការធ្វើអាជីវកម្មឡូត៍នេសាទដូចខាងក្រោម :

១- ធ្វើនេសាទហួសពីព្រំប្រទល់ឡូត៍នេសាទ ឬខុសពីទីតាំងឡូត៍នេសាទ។

២- ធ្វើនេសាទដោយប្រើមធ្យោបាយផ្សេងៗ ទោះមើលឃើញក្តី មើលមិនឃើញក្តី ដើម្បីចាប់ត្រីពីក្រៅឡូត៍នេសាទ។

៣- ធ្វើនេសាទដោយប្រើឧបករណ៍គ្រប់ប្រភេទ ដើម្បីហ៊ុម ឬកៀរជាលើកទីពីរ បន្ទាប់ពីការហ៊ុម ឬកៀរលើកទីមួយម្តងហើយ ចំពោះឡូត៍នេសាទបឹងព្រែក និងឡូត៍នេសាទប្រើឧបករណ៍ ណ រត់ ឈូង នៅក្នុងបឹងទន្លេសាប។

ប្រការ ១៣: ប្រជាពលរដ្ឋ ដែលមានទីលំនៅក្នុងឡូត៍នេសាទ អ្នកនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្ម អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម :

ក- <u>ប្រជាពលរដ្ឋដែលមានទីលំនៅក្នុងឡូត៍នេសាទ</u> :

១- អាចធ្វើដំណើរដឹកជញ្ជូនទំនិញគ្រប់ប្រភេទ ឬផលនេសាទដែលចាប់បានក្រៅពីឡូត៍នេសាទឆ្លងកាត់ចុះឡើងបាន ប៉ុន្តែហាមធ្វើឱ្យរាំងស្ទះដល់ការធ្វើអាជីវកម្មនេសាទ។

២- អាចប្រើប្រាស់ទឹកសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ ដើម្បីបង្កបង្កើនផលស្រូវ និងដំណាំផ្សេងៗ ប៉ុន្តែហាមបង្ហូរ ឬបិទទឹក ដែលធ្វើឱ្យមានការប្រែប្រួលរបបទឹក និងធ្វើឱ្យខូចដល់ការធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទ។

៣- អាចធ្វើនេសាទក្នុងកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ។

ខ- <u>អ្នកនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្ម</u> :

នៅក្នុងរយៈពេលបើកនេសាទនៃឡូត៍នេសាទ ត្រូវហាមឃាត់ការធ្វើនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្មក្នុងកន្លែងនេសាទបម្រុងត្រង់ចំណុច ដែលមានចំងាយ ២០០ ម៉ែត្រ ពី :

- ព្រំប្រទល់ឡូត៍បឹងព្រែកផ្នែកខាងមុខច្រកចេញ ចូលចរាចរត្រី ឬផ្នែកខាងបរិវេណដែលប្រើរបាំងព្រួល។
- មុខឡូត៍ដាយគ្រប់ប្រភេទ។

គ- <u>អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ</u> :

១- ត្រូវគោរពតាមការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអនុញ្ញាតតាមសំណើរបស់រដ្ឋបាលជលផលឱ្យប្រជាពលរដ្ឋធ្វើទំនប់ រំលាយទំនប់ ឬជីកប្រឡាយ ដើម្បីផលប្រយោជន៍ដល់ការបង្កបង្កើនផលស្រូវ ឬដំណាំផ្សេងៗ។

២- មិនត្រូវសាងសង់លំនៅដ្ឋានជាអចិន្ត្រៃយ៍សម្រាប់បម្រើការធ្វើអាជីវកម្ម ឬសម្រាប់ការរស់នៅរបស់កម្មករ ដែលបម្រើការងារឡូត៍នេសាទ នៅក្នុងឡូត៍នេសាទឡើយ ។

៣- ក្នុងករណីគ្មានសេចក្តីសម្រេចពាក់ព័ន្ធនឹងចំណុច ១ ខាងលើ ហាមធ្វើសកម្មភាពអ្វីទាំងអស់ដែលធ្វើឱ្យមានការប្រែប្រួលរបបទឹក ឬរំខានដល់ចរាចរនៃជលយានតូចៗ ដែលធ្វើដំណើរឆ្លងកាត់ចុះឡើង និងការធ្វើអាជីវកម្មនេសាទ ។

ក្នុងករណីមានវិវាទរវាងប្រជាពលរដ្ឋ និងអ្នកដែលទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវបង្កើតគណៈកម្មការមួយ ដើម្បីដោះស្រាយទំនាស់ ដែលមានសមាសភាពដូចខាងក្រោម:

១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ជាប្រធាន

២- ប្រធានរដ្ឋបាលជលផល ឬតំណាង ជាអនុប្រធាន

៣- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង ជាសមាជិក

៤- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង ជាសមាជិក

៥- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង ជាសមាជិកអចិន្ត្រៃយ៍

៦- អភិបាលនៃគណៈអភិបាលក្រុង ខណ្ឌ ឬស្រុកដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

៧- មេឃុំ ឬចៅសង្កាត់ដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

ករណីដោះស្រាយមិនបាន ត្រូវធ្វើសំណើមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសម្រេច ។

ប្រការ ១៤ : ក្រៅពីការគោរពឱ្យបានត្រឹមត្រូវតាមបទបញ្ជាទាំងឡាយ ដែលមានចែងក្នុងសៀវភៅបន្ទុកនេះ ឬតាមកិច្ចសន្យា អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវគោរពតាមខ្លឹមសារនៃច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផលថែមទៀត ។

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវទទួលខុសត្រូវចំពោះបទល្មើសជលផល ដែលសាមីខ្លួន សមាជិកក្នុងក្រុម ឬកម្មកររបស់ខ្លួនបាន ឬកំពុងប្រព្រឹត្ត ។

ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ :

- ទទួលមរណភាព ឬបាត់បង់សមត្ថភាព ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលជលផលត្រូវរៀបចំសំណុំបែបបទដើម្បីផ្ទេរទៅឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ទទួលខុសត្រូវជំនួសតាមការស្នើសុំ ។ ក្នុងករណីគ្មានជនណាម្នាក់ហ៊ានទទួលខុសត្រូវជំនួស ឡូត៍នេសាទទាំងមូលត្រូវដកហូតវិញ ដើម្បីរៀបចំដេញថ្លៃសារជាថ្មី ។ ករណីមិនអាចរៀបចំដេញថ្លៃជាថ្មីបាន អាចដូលតាមការកំណត់របស់សមត្ថកិច្ចរដ្ឋបាលជលផល និងស្នើសុំសេចក្តីសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- បោះបង់ឡូត៍នេសាទចោល ឬមិនគោរពកិច្ចសន្យា និងសៀវភៅបន្ទុក ឡូត៍នេសាទទាំងមូលត្រូវដកហូត និងប្រាក់កក់ធានាស្លាកត្រូវរឹបអូស ព្រមទាំងបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បី

ទាមទារសំណងការខូចខាតពីអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទដែលបានបង្កឡើង។

- ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្ទុយនឹងច្បាប់ស្តីពីជលផល ឬលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យជលផល ឡូត៍នេសាទទាំងមូលត្រូវដកហូត និងបញ្ជូនសំណុំរឿងទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

គ្រប់ករណីខាងលើនេះ បើអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទមិនបង់ប្រាក់ឱ្យគ្រប់ចំនួនតាមការកំណត់ក្នុងសៀវភៅបន្ទុកនេះ ឬតាមកិច្ចសន្យា ឧបករណ៍សម្រាប់ធ្វើនេសាទត្រូវរឹបអូសតាមផ្លូវច្បាប់ដើម្បីលក់ទូទាត់ប្រាក់ឱ្យបានគ្រប់ចំនួន។ បន្ថែមពីលើនេះទៀត ជនល្មើសត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានថែមទៀត។

ប្រការ ១៥ : សៀវភៅបន្ទុកនេះ មានសុពលភាពអនុវត្តរយៈពេល ២ រដូវនេសាទ គឺស្មើនឹង ១ អាណត្តិនេសាទ។ ក្នុងករណីឡូត៍នេសាទត្រូវបានដកហូតមុនអាណត្តិនេសាទ សុពលភាពនៃសៀវភៅបន្ទុកនេះក៏ត្រូវបញ្ចប់ស្របតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០ ...

ប្រធានរដ្ឋបាលជលផល

បានឃើញ និង យល់ព្រម

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០ ...

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៤៦ ប្រ.ក កសក

លិខិតចូល

ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១០

ប្រកាស

ស្តីពី

នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហការប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្ម និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៥អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

ប្រការ ១: ប្រកាសនេះ សំដៅកំណត់នូវនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ ក្នុងការនាំចេញ នាំចូល ឆ្លងកាត់ ដឹកជញ្ជូនក្នុងព្រះរាជាណាចក្រកម្ពុជា នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ក្នុងគោលបំណង ទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដើម្បីការពារផលិតកម្មកសិកម្ម ជីវសាស្ត្រចម្រុះ និងសម្រួលសកម្មភាពពាណិជ្ជកម្មជាអន្តរជាតិ។

ប្រការ ២: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការនាំចេញ នាំចូល ឆ្លងកាត់ ដឹកជញ្ជូនក្នុងព្រះរាជាណាចក្រកម្ពុជា នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវសុំការត្រួតពិនិត្យតាមនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ និងត្រូវគោរពតាមគ្រប់វិធានភូតគាមអនាម័យ។

ប្រការ ៣: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូលនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) និង/ឬ វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត (Phytosanitary Certificate for Re Export) ដែលចេញដោយប្រទេសនាំចេញ និង/ឬ ប្រទេសនាំចេញបន្ត (ជាគំរូច្បាប់ដើម)
- វិញ្ញាបនបត្រធូបទកម្ម (Fumigation Certificate) ក្នុងករណីដែលទំនិញបានធ្វើធូបទកម្ម មុនចូលមកដល់កម្ពុជា
- លិខិតអនុញ្ញាតនាំចូល (Import Licence for Agricultural Material) ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្នុងករណីដែលទំនិញជាសម្ភារៈកសិកម្ម មាន ពូជដំណាំ ជីថ្នាំកសិកម្ម ចំណីសត្វ ជាដើម)
- វិក្កយបត្រទំនិញ (Invoice) បញ្ជីវេចខ្ចប់ (Packing List) និងបញ្ជីផ្ទុកទំនិញ (Bill of lading) ។

គំរូពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល និងកំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១ និង ២ នៃប្រកាសនេះ ។

ប្រការ ៤: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលមានសក្តានុពលហានិភ័យខ្ពស់នៃសមាសភាពចង្រៃ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសនេះ ត្រូវបំពេញសំណុំបែបបទស្នើសុំជាមុននូវវិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/Permit for Plant Quarantine Materials) នៅអគ្គនាយកដ្ឋានកសិកម្ម ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- បញ្ជីឈ្មោះសមាសភាពចង្រៃមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញដែលស្នើសុំក្នុងប្រទេសជាប្រភពដើមនៃទំនិញ
- បញ្ជីឈ្មោះសមាសភាពចង្រៃមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញដែលស្នើសុំក្នុងប្រទេសដែលត្រូវដឹកជញ្ជូនឆ្លងកាត់ (ក្នុងករណីត្រូវឆ្លងកាត់ប្រទេសទី ២ មុនមកដល់កម្ពុជា)
- ឯកសារបច្ចេកទេសប្រព្រឹត្តកម្មនានា លើទំនិញដែលស្នើសុំ ។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវឆ្លើយតបអំពីលទ្ធផលនៃការវិភាគហានិភ័យ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីទទួលបានសំណុំឯកសារខាងលើ ។

នៅពេលនាំចូល រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលជាម្ចាស់ទំនិញ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូលនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ , ដោយភ្ជាប់មកជាមួយនូវឯកសារ ដូចបានកំណត់ក្នុងប្រការ ៣ និងផ្តល់បន្ថែមនូវ:

- វិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/ Permit for Plant Quarantine Materials) ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម
- ឯកសារផ្សេងទៀតតាមការតម្រូវរបស់វិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/ Permit for Plant Quarantine Materials) ដែលចេញដោយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេសនាំចេញ និង/ឬ នាំចេញបន្ត ។

គំរូពាក្យសុំនាំចូលទំនិញដែលជាកម្មវត្ថុត្រួតពិនិត្យភូតគាមអនាម័យ និង គំរូវិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ៤ និង ៥ នៃប្រកាសនេះ ។

ប្រការ ៥: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចេញ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ នៅអគ្គនាយកដ្ឋានកសិកម្ម យ៉ាងតិចក្នុងរយៈពេល ១០ថ្ងៃ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- វិក្កយបត្រ (Invoice) និងបញ្ជីវេចខ្ចប់ (Packing list)

- វិញ្ញាបនបត្រធូបទកម្ម (Fumigation certificate) (ប្រសិនបើមាន)
- លិខិតអនុញ្ញាតនាំចូល (Import Permit issued by the importing country) (ប្រសិនបើមាន)
- បណ្ណាលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល (ប្រសិនបើមាន)
- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសជាប្រភពដើមនៃទំនិញ (ក្នុងករណីសុំនាំចេញបន្ត)

គំរូសំណុំពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ កំណត់ហេតុស្ដីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ វិញ្ញាបនបត្រភូតគាមអនាម័យលើទំនិញនាំចេញ និងវិញ្ញាបនបត្រភូតគាមអនាម័យលើទំនិញសម្រាប់នាំចេញបន្ត ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ៦, ៧, ៨ និង ៩ នៃប្រកាសនេះ។

ប្រការ ៦: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងដឹកជញ្ជូនឆ្លងកាត់នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញដឹកជញ្ជូនឆ្លងកាត់នៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យច្រកទ្វារនាំចូល ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- វិក្កយបត្រទំនិញ (Invoice) បញ្ជីវេចខ្ចប់ (Packing List) និងបញ្ជីផ្ទុកទំនិញ (Lading bill)
- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) និង/ឬ វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត (Phytosanitary Certificate for Re Export) ដែលចេញដោយប្រទេសនាំចេញ និង/ឬ ប្រទេសនាំចេញបន្ត (ជាគំរូច្បាប់ដើម)
- វិញ្ញាបនបត្រធូបទកម្ម (Fumigation Certificate) ក្នុងករណីដែលទំនិញបានធ្វើធូបទកម្ម មុនចូលមកដល់កម្ពុជា

ម្ចាស់ទំនិញត្រូវបង្ហាញសំណុំបែបបទខាងលើ នៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យច្រកទ្វារចេញ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុស្ដីពីការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ ដែលបានទទួលពីច្រកទ្វារចូល។

គំរូសំណុំឯកសារសម្រាប់ស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ និងកំណត់ហេតុស្ដីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១០ និង ១១ នៃប្រកាសនេះ។

ប្រការ ៧: រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងដឹកជញ្ជូន ចេញ ចូល ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យពីតំបន់ណាមួយនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសជាតំបន់រាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់

ត្រូវសុំការត្រួតពិនិត្យភូតគាមអនាម័យ ទៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យបណ្តោះអាសន្នណាមួយដែលនៅជិតបំផុត ដោយត្រូវគោរពតាមវិធានភូតគាមអនាម័យ ដូចខាងក្រោមៈ

ក. ផ្អាកទាំងស្រុងចំពោះការដឹកជញ្ជូន ឬ យកចេញ ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ជាជម្រកភាគត្បាតផ្ទាល់របស់សមាសភាពចង្រៃ ដែលកំពុងរាលដាលឆ្លង រហូតដល់សមត្ថកិច្ចភូតគាមអនាម័យធ្វើការកំចាត់បានទាំងស្រុង។

ខ. ការដឹកជញ្ជូន ឬ យកចេញ ចូល ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ មិនមែនជាជម្រកភាគត្បាតផ្ទាល់របស់សមាសភាពចង្រៃដែលកំពុងរាលដាលឆ្លង អាចធ្វើទៅបានក្រោយពីបានត្រួតពិនិត្យ និងទទួលការអនុញ្ញាតពីសមត្ថកិច្ចភូតគាមអនាម័យ។

គំរូពាក្យស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យ លើការដឹកជញ្ជូនទំនិញជាកម្មវត្ថុត្រួតពិនិត្យភូតគាមអនាម័យក្នុងប្រទេស ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១២ ១៣ និង ១៤ នៃប្រកាសនេះ។

ប្រការ ៨: ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩: អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ច័ន្ទ សារុន

កន្លែងទទួលៈ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ ៩
- ឯកសារ - កាលប្បវត្តិ ៦

ឧបសម្ព័ន្ធ ១ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ (No)...................

ពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូល
(Application for Plant Quarantine Inspection of Import Consignment)

សម្រាប់សមត្ថកិច្ច ភ.គ.អ (FOR PQ AUTHORITY)
• លេខកូដ (CODE No):... ....
• ចំណាត់ការ (DECISION):...

នាម និងគោត្តនាមអ្នកសុំ (APPLICANT'S NAME) : ....

ឈ្មោះក្រុមហ៊ុន (COMPANY NAME) : ....

អាស័យដ្ឋានក្រុមហ៊ុន និងទូរស័ព្ទទំនាក់ទំនង (COMPANY ADDRESS & CONTACT PHONE'S NUMBER) : ....

សូមគោរពជូន

សមត្ថកិច្ចភូតគាមអនាម័យប្រចាំ ....
TO THE PLANT QUARANTINE AUTHORITY OF

កម្មវត្ថុ: (Subject)	សុំការត្រួតពិនិត្យនាំចូល: .... (APPLY FOR IMPORT INSPECTION OF)..

ឯកសារជូនភ្ជាប់ (ATTACHED DOCUMENTS):

			សំគាល់ (NOTE):
1.	វិញ្ញាបនបត្រភូតគាមអនាម័យ ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចេញ (PHYTOSANITARY CERTIFICATE ISSUED BY PQ AUTHORITY OF EXPORTED COUNTRY)	☐	1. ចាំបាច់ត្រូវតែមាន (NESSESSARY DOCUMENT)
2.	វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចេញបន្ត (PHYTOSANITARY CERTIFICATE FOR RE EXPORT ISSUED BY PQ AUTHORITY OF RE EXPORTED COUNTRY)	☐	2. ប្រសិនបើនាំចេញពីប្រទេសទី ២ (IN CASE OF EXPORT FROM 2nd COUNTRY)
3.	វិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម (IMPORT CERTIFICATE/PERMIT FOR PLANT QUARANTINE MATERIALS, ISSUED BY GDA OF MAFF)	☐	3. សម្រាប់ទំនិញដែលមានហានិភ័យខ្ពស់ (FOR PQ HIGH RISK GOODS)
4.	ឯកសារផ្សេងទៀតតាមការតម្រូវនៃឯកសារជូនភ្ជាប់ទី ៣ ដែលចេញដោយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេសនាំចេញ និង/ឬ នាំចេញបន្ត (OTHER DOCUMENTS AS REQUIREO BY 2nd ATTACHED DOCUMENT ISSUED BY EXPORT AND/OR RE EXPORT COUNTRIES)	☐	4. សម្រាប់ទំនិញដែលមានហានិភ័យខ្ពស់ (FOR PQ HIGH RISK GOODS)
5.	វិញ្ញាបនបត្រធូបទកម្ម (FUMIGATION/DISINFESTATION CERTIFICATE)	☐	5. ប្រសិនបើមាន (IF AVAILABLE)
6.	លិខិតអនុញ្ញាតនាំចូលសម្ភារៈកសិកម្ម ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (IMPORT LICENSE FOR AGRICULTURAL MATERIALS ISSUED BY MAFF)	☐	6. សម្រាប់ទំនិញជាសម្ភារៈកសិកម្ម (FOR AGRICULTURAL MATERIAL)
7.	វិក្កយបត្រទំនិញ (INVOICE) និងបញ្ជីវេចខ្ចប់ (& BACKING LIST)	☐	7. ចាំបាច់ត្រូវតែមាន / (NESSASSARY DOCUMENT)
8.	បញ្ជីផ្ទុកទំនិញ (BILL OF LADING)	☐	8. ចាំបាច់ត្រូវតែមាន (NESSASSARY DOCUMENT)

សំគាល់ (NOTE): សូមគូស ☑ ចំពោះឯកសារជូនភ្ជាប់ដែលមាន (PLEASE MAKE A NOTE ☑ FOR AVAILABLE ATTACHED DOCUMENTS)

ការពិពណ៌នាអំពីមុខទំនិញ (DESCRIPTION OF GOODS):

១.បំណងនៃការនាំចូលទំនិញ (1. IMPORT PURPOSE)	:................................	២.ផ្លូវបន្តដឹកទំនិញ (2.TRANSPORTS WAY OF GOODS)	:................................
៣.កន្លែងរក្សាទុកទំនិញ (3. PLACE TO STORE OF GOODS)	:................................	៤.កន្លែងយកទៅដាំដុះ (4. PLACE OF PROPAGATION)	:................................

សេចក្តីថ្លែងរបស់អ្នកស្នើសុំ (APPLUCANT'S STATEMENT)

នាងខ្ញុំ/ខ្ញុំបាទ/ក្រុមហ៊ុនយើងខ្ញុំ សូមប្រកាសថា ឯកសារជូនភ្ជាប់ និងព័ត៌មានទាំងអស់ខាងលើ ពិតជាត្រឹមត្រូវមិនមានការក្លែងបន្លំ និងគោរពតាមវិធានការភូតគាមអនាម័យ ។
(I WOULD LIKE TO CERTIFY THAT ALL ATTACHED DOCUMENTS AND INFORMATIONS DECLARED ABOVE ARE TRUE, AND RESPECT TO ALL PHYTOSANITARY TREATMENT AS REQUIRED).

ច្រកទ្វារ, កាលបរិច្ឆេទ (CHECK POINT, DATE)

ហត្ថលេខា និង/ឬត្រាក្រុមហ៊ុនដែលស្នើសុំ (SIGNATURE AND STAMP OF COMPANY)

ឧបសម្ព័ន្ធ ២ នៃប្រកាសលេខ ចុះថ្ងៃទ ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ Nation Religion King

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MINISTRY OF AGRICULTURE FORESTRY AND FISHERIES

សមត្ថកិច្ចភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
PLANT QUARANTINE AUTHORITY OF
GENERAL DIRECTORATE OF AGRICULTURE

ប្រចាំ (AT) :................................

លេខ (No) :....... ....

លេខកូដស្នើសុំ (APPYING CODE No) ... .

កំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល

(REPORT OF PLANT QUARANTINE INSPECTION OF IMPORT CONSIGNMENT)

កាលបរិច្ឆេទ និងម៉ោងត្រួតពិនិត្យ (DATE & TIME OF INSPECTION) :..

នាម និងគោត្តនាមភ្នាក់ងារត្រួតពិនិត្យ (INSPECTORS'S NAMES) :..

នាម និងគោត្តនាម និងមុខងារអ្នកចូលរួម (NAME & FUNCTION OF PARTICIPANTS) :..
....

១. លទ្ធផលនៃការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង (RESULT OF IN PLACE INSPECTION):

a. ការវេចខ្ចប់ត្រឹមត្រូវ (PROPER PACKAGED) ☐	b. ការវេចខ្ចប់មិនត្រឹមត្រូវ/បរិយាយ (UNPROPER PACKAGED/ DESCRIPTION) ☐	:..............................
c. អវត្តមានសមាសភាពចង្រៃរស់ (NO LIVING PEST) ☐	d. វត្តមានសមាសភាពចង្រៃរស់ (DETECTION OF LIVING PEST) ☐	:..............................
e. អវត្តមានសមាសភាពចង្រៃងាប់ (NO DEAD PEST) ☐	f. វត្តមានសមាសភាពចង្រៃងាប់/បរិយាយ (DETECTION OF DEAD PEST/ DESCRIPTION) ☐	:..............................
g. គ្មានសញ្ញាសង្ស័យនៃការរាតត្បាត (NO SUSPECTED SYMPTOM) ☐	h. មានសញ្ញាសង្ស័យនៃការរាតត្បាត/បរិយាយ (SUSPECTED SYMPTOM/DESCRIPTION) ☐	:..............................
i. ការសន្និដ្ឋានលើការត្រួតពិនិត្យផ្ទាល់ (CONCLUSION OF IN PLACE INSPECTION)	:..............................	

២. លទ្ធផលនៃការវិភាគនៅមន្ទីរពិសោធន៍ភោគវិនិច្ឆ័យ (RESULT OFDIAGNOSIS'S LAB,TEST):

a. ចំនួនសំណាកដែលត្រូវវិភាគ:.......... (No. OF SAMPLES)	b. នាម និងគោត្តនាមមន្ត្រីទទួលខុសត្រូវ (NAME OF RESPONSIBLE OFFICER) :..............................	
c. កាលបរិច្ឆេទចាប់ផ្តើម :.............. (STARTED DATE)	d. កាលបរិច្ឆេទបញ្ចប់ :..... .. .. (COMPLETED DATE)	e. លទ្ធផល (RESULTED) :..............................

៣. ការសម្រេចរបស់សមត្ថកិច្ច ភ.គ.អ (DECISION OF PQ AUTHORITY):

a. អនុញ្ញាតជម្រះទំនិញ (CLERANCE) ☐	b. កែសម្រួលការវេចខ្ចប់ (RE PACKAGE) ☐	c. ធូបទកម្ម (FUMIGATION) ☐	d. បាញ់ថ្នាំផ្ទៃខាងក្រៅ (DISINFESTATION) ☐
e. ប្តូរគោលដៅប្រើប្រាស់ទំនិញ (CHANCE OF USE'S PURPOSE) ☐ :..............................		f. វិធាន ភ.គ.អ ផ្សេងទៀត (OTHER PQ TREATMENT) ☐	:..............................
g. ស្នើកម្ទេចទំនិញចោល (DESTROY OF GOODS) ☐	h. ស្នើបញ្ជូនទៅប្រទេសដើម (SEND BACK TO ORIGIN) ☐	i. ការឯកភាពពីក្រសួង (MAFF APPROVAL LETTER) ☐	:..............................
j. ការបញ្ជាក់របស់ ភ.គ.អ បន្ទាប់ពីចំណាត់វិធាន ភ.គ.អ (PQ CERTIFY AFTER PQ TREATENTED) :..............................			

សំគាល់ (NOTE): ការសម្រេចនៃវិធាន 3g និង 3h អាស្រ័យដោយ 3i (THE DECISIONS IN POINT 3g OR 3h IS DEPEND ON 3i)

៤. ការចុះហត្ថលេខាឯកភាព (APPROVED SIGNATURES)

ម៉ោង/កាលបរិច្ឆេទបញ្ចប់របាយការណ៍ (TIME & DATE OF REPORT COMPLETION)	....	អ្នកធ្វើកំណត់ហេតុ (REPORTER)	....
ម្ចាស់ទំនិញ ឬតំណាង (GOODS OWNER/REPRESENTATIVE)	....	សមត្ថកិច្ច ភ.គ.អ (PQ AUTHORITY)	....

ឧបសម្ព័ន្ធ ៣ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលមានសក្តានុពលហានិភ័យសមាសភាពចង្រៃខ្ពស់រួមមានៈ

- ពូជ និងបំណែកពូជរុក្ខជាតិ សម្រាប់ដាំដុះបន្ត ពូជដំណាំជាលិកាវប្បកម្ម (Tissue culture) ប្រភេទរុក្ខជាតិធ្វើតេស្ត ដកយកចេញពីមេបាដើម ជាលិកាបណ្តុះសារពាង្គកាយដែលបានកែសំរួលហ្សែន
- សត្វល្អិតរស់ អតិសុខុមប្រាណ ភ្នាក់ងារជីវសាស្ត្រ ផ្សិត
- អាល់ប្កា ដី ឬ ដីកំប៉ុស្តិ៍ ដែលកើតឡើងពីកំទេចកំទីរុក្ខជាតិពុកផុយប្រើសម្រាប់បណ្តុះឬដាំ ឬ បង្កើនជីជាតិដី
- ផលិតផល បន្លែ ផ្លែឈើស្រស់ និង មើម ឬ ពន្លកក្តៀងស្រស់ និងពពួកស្លែ ដែលមានបំណងនាំចូលពីប្រទេសជាប្រភព ដែលមិនធ្លាប់នាំចូលមកកម្ពុជា
- បណ្តាទំនិញដទៃទៀតដែលចាត់ក្នុងកម្រិតហានិភ័យនៃស្តង់ដារភូតគាមអនាម័យអន្តរជាតិលេខ ៣២ មាន ទី ៣ និង ទី ៤ ស្តីពីចំណាត់ថ្នាក់ទំនិញអាស្រ័យលើកម្រិតហានិភ័យបង្កឡើងដោយសមាសភាពចង្រៃ ។

ឧបសម្ព័ន្ធ ៤ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ (No)..................

ពាក្យសុំនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
(Application for Importing of Plant Quarantine Materials)

សម្រាប់សមត្ថកិច្ច ភ.គ.អ (FOR PQ AUTHORITY)	
• លេខកូដស្នើសុំ :.............	
• ចំណាត់ការ:	

នាម និង គោត្តនាមអ្នកសុំ (APPLICANT'S NAME) ....

ឈ្មោះក្រុមហ៊ុន (COMPANY NAME) ....

អាស័យដ្ឋានក្រុមហ៊ុន និងទូរស័ព្ទទំនាក់ទំនង (COMPANY ADDRESS & CONTACT PHONE'S NUMBER) ....
....
....

សូមគោរពជូន

ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម

កម្មវត្ថុ: (Subject)	សុំគោលការណ៍អនុញ្ញាតនាំចូល: .... (APPLY FOR IMPORT OF) ....

ឯកសារជូនភ្ជាប់ (ATTACHED DOCUMENTS):

- បញ្ជីឈ្មោះសមាសភាពចង្រៃដែលមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញកំពុងស្នើសុំ ក្នុងប្រទេសកំណើតនៃទំនិញ (THE LIST OF ENDEMIC AND STORED PEST OF APPLYING GOODS IN THE PLACE OF ORIGIN) ☐ (ចាំបាច់ត្រូវតែមាន) (NESSASSARY DOCUMENT)
- បញ្ជីឈ្មោះសមាសភាពចង្រៃដែលមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញកំពុងស្នើសុំ ក្នុងប្រទេសដឹកជញ្ជូនឆ្លងកាត់ (THE LIST OF ENDEMIC AND STORED PEST OF APPLYING GOODS IN THE PLACE OF TRANSIT) ☐ (ប្រសិនបើត្រូវដឹកជញ្ជូនឆ្លងកាត់) (IN CASE OF TRANSIT IN OTHER COUNTRIES)
- ឯកសារបច្ចេកទេសប្រព្រឹត្តកម្មនានាលើទំនិញកំពុងស្នើសុំ ដែលមានអំពើកម្ចាត់សមាសភាពចង្រៃ (TECHNICAL/TREATMENT DOCUMENTS SUPPORTED IN PEST DISINFESTATION OF APPLYING GOODS) ☐ (ប្រសិនបើមាន) (IF AVAILABLE)

សំគាល់ (NOTE): សូមគូស ☑ចំពោះឯកសារជូនភ្ជាប់ដែលមាន (PLEASE MAKE A NOTE ☑ FOR AVAILABLE ATTACHED DOCUMENTS)

ការពិពណ៌នាអំពីមុខទំនិញ (DESCRIPTION OF GOODS):

១.ឈ្មោះទូទៅនៃទំនិញ (1. COMMON NAME OF GOODS)	....	២.ឈ្មោះវិទ្យាសាស្ត្រនៃទំនិញ (2.BOTANICAL NAME OF GOODS)	....
៣.បរិមាណទំនិញ (3. GOODS'S QUANTITY)	....	៤.ការវេចខ្ចប់ទំនិញ (4. DESCRIPTION OF PACKAGE)	....
៥.បំណងនៃការនាំចូលទំនិញ (5. IMPORT PURPOSE)	....	៦.ច្រកទ្វារនាំចូលទំនិញ (6. POINT OF ENTRY)	....
៧.ប្រទេសប្រភពទំនិញ (7. PLACE OF ORIGIN)	....	៨.ប្រទេសឆ្លងកាត់ (8. CONTRY'S TRANSIT)	....

សេចក្តីថ្លែងរបស់អ្នកស្នើសុំ (APPLICANT'S STATEMENT)

នាងខ្ញុំ/ខ្ញុំបាទ/ក្រុមហ៊ុនយើងខ្ញុំ សូមប្រកាសថា ឯកសារជូនភ្ជាប់ និងព័ត៌មានទាំងអស់ខាងលើ ពិតជាត្រឹមត្រូវមិនមានការក្លែងបន្លំ និងសន្យាថា នឹងផ្តល់បន្ថែមនូវបណ្តាព័ត៌មានពាក់ព័ន្ធទៅនឹងទំនិញស្នើសុំ ដើម្បីសម្រួលដល់ដំណើរការវិភាគហានិភ័យសមាសភាពចង្រៃ ដែលអាចបង្កឡើងដោយការនាំចូលទំនិញដែលស្នើសុំ និងគោរពតាមរាល់វិធានការភូតគាមអនាម័យ ។ (I WOULD LIKE TO CERTIFY THAT ALL ATTACHED DOCUMENTS AND INFORMATIONS DECLARED ABOVE ARE TRUE AND PROMISE THAT WILL SUBMIT OTHER RELATED DOCUMENTS AS REQUIRED FOR FILLFULL THE PROCESS OF PEST RISK ANALYSIS AND RESPECT TO ALL PHYTOSANIT/ TREATMENT AS REQUIRED).

ភ្នំពេញ, ថ្ងៃទី .... (PHNOM PENH, DATE)

ហត្ថលេខា និងត្រាក្រុមហ៊ុនដែលស្នើសុំ .... (SIGNATURE AND STAMP OF COMPANY)

ឧបសម្ព័ន្ធ ៥ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

KINGDOM OF CAMBODIA

Nation Religion King

GENERAL DIRECTORATE OF AGRICULTURE
PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

IMPORT CERTIFICATE FOR PLANT QUARANTINE MATERIAL

No:............

Permission is hereby granted to Import Plant Quarantine Material in accordance with: the Sub-Degree on Phytosanitary Inspection, No. 15 Or. Nor.Kro dated 13 March 2003 and Law on the Management of Quality and Safety of Products and Services dated 21 June 2000.

Name and Address of Importer	Name and Address of Exporter	
Country of Origin	**Entry point**	
Botanical Name	**Common Name/Variety**	**Quantity (Wt/No.)**
		GW : NW :

General Entry Conditions

The Consignment of plants/seeds should be:

(i) Free from soil and weed seeds

(ii) Accompanies by and official Phytosanitary Certificate by the authorized officer at the country of origin

(iii) ....

Special Entry Conditions

PEQ Requirements

For a period of......... Days.

Date of Issue: ...../...../....... Place of Issue: PHNOM PENH Validity Date: ...../......./.......

(Signature & Stamp of GDA Director General)	(Signature of PP-SPSD Director)
GENERAL DIRECTOETAE OF AGRICALTURE	PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

SAMPLE

PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT. NO. 54B, St 656, Sangkat Toeuk Laak 3, Khan Toul Kok, P-Penh, Cambodia
Tel: (855) 23 885 482, Fax: (023) 883 267. EMAIL: ppspsdcam@online.com.kh

ឧបសម្ព័ន្ធ ៦ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ (No)..................

ពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចេញ
(Application for Plant Quarantine Inspection of Export Consignment)

នាម និងគោត្តនាមអ្នកសុំ (APPLICANT'S NAME) ....

ឈ្មោះក្រុមហ៊ុន (COMPANY NAME) ....

អាសយដ្ឋានក្រុមហ៊ុន និងទូរស័ព្ទទំនាក់ទំនង (COMPANY ADDRESS & CONTACT PHONE'S NUMBER) ....

សម្រាប់សមត្ថកិច្ច ភ.គ.អ (FOR PQ AUTHORITY)
• លេខកូដស្នើសុំ :..............
• ចំណាត់ការ: ....

សូមគោរពជូន

ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម
(TO H.E DIRECTOR GENERAL OF GENERAL DIRECTORATE OF AGRICULTURE)

កម្មវត្ថុ: (Subject)	សុំការត្រួតពិនិត្យនាំចេញ ☐/នាំចេញបន្ត ☐: .... (APPLY FOR EXPORT☐/RE EXPORT ☐ INSPECTION OF)................................

ឯកសារភ្ជាប់ (ATTACHED DOCUMENTS):

		សំគាល់ (NOTE):
1. វិញ្ញាបនបត្រភូតគាមអនាម័យ ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យក្នុងប្រទេសជាប្រភពដើមនៃទំនិញ (PHYTOSANITARY CERTIFICATE ISSUED BY PQ AUTHORITY OF COUNTRY'S ORIGIN)	☐	1. ចំពោះការនាំចេញបន្ត (FOR RE EXPORT)
2. លិខិតអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យ នៃប្រទេសនាំចូល (IMPORT CERTIFICATE/PERMIT FOR PLANT QUARANTINE MATERIALS, ISSUED BY PQ AUTHORITY OF IMPORTING COUNTRY)	☐	2. សម្រាប់ទំនិញដែលមានហានិភ័យខ្ពស់(FOR PQ HIGH RISK GOODS)
3. បញ្ញាត្តិតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល (OTHER DOCUMENTS RELATED TO PQ REQUIEMENT OF IMPORTING COUNTRY)	☐	3. ប្រសិនបើមាន (IF AVAILABLE)
4. វិញ្ញាបនបត្រធូបនកម្ម (FUMIGATION/DISINFESTATION CERTIFICATE)	☐	4. ប្រសិនបើមាន (IF AVAILABLE)
5. វិក្កយបត្រទំនិញ (INVOICE)	☐	5. ចាំបាច់ត្រូវតែមាន (NESSASSARY DOCUMENT)
6. បញ្ជីវេចខ្ចប់ (PACKING LIST)	☐	6. ចាំបាច់ត្រូវតែមាន (NESSASSARY DOCUMENT)

សំគាល់ (NOTE): សូមគូស ☑ ចំពោះឯកសារភ្ជាប់ដែលមាន (PLEASE MAKE A NOTE ☑ FOR AVAILABLE ATTACHED DOCUMENTS)

ការពិពណ៌នាអំពីមុខទំនិញ (DESCRIPTION OF GOODS):

១.បំណងនៃការនាំចេញ (1 EXPORT PURPOSE)	....	២.មធ្យោបាយដឹកជញ្ជូន (2 MEAN OF CONVEYANCE)	....
៣.ច្រកចេញ (3 EXIT POINT)	....	៤.ច្រក និងប្រទេសគោលដៅ (4. ENTRY AND COUNTRY DESTINATION)	....
ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុន ដែលទទួលទំនិញ (NAME & ADDRESS OF CONSIGNEE)	....		

សេចក្តីថ្លែងរបស់អ្នកស្នើសុំ (APPLICANT'S STATEMENT)

នាងខ្ញុំ/ខ្ញុំបាទ/ក្រុមហ៊ុនយើងខ្ញុំ សូមប្រកាសថា ឯកសារជូនភ្ជាប់ និងព័ត៌មានទាំងអស់ខាងលើ ពិតជាត្រឹមត្រូវមិនមានការក្លែងបន្លំ និងគោរពតាមវិធានការភូតគាមអនាម័យ។ (I WOULD LIKE TO CERTIFY THAT ALL ATTACHED DOCUMENTS AND INFORMATIONS DECLARED ABOVE ARE TRUE, AND RESPECT TO ALL PHYTOSANITARY TREATMENT AS REQUIRED)

ភ្នំពេញ, កាលបរិច្ឆេទ (PHNOM PENH, DATE) ....

ហត្ថលេខា និងត្រាក្រុមហ៊ុនដែលស្នើសុំ (SIGNATURE AND STAMP OF COMPANY) ....

ឧបសម្ព័ន្ធ ៧ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ Nation Religion King

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MINISTRY OF AGRICULTURE FORESTRY AND FISHERIES

សមត្ថកិច្ចភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
PLANT QUARANTINE AUTHORITY OF
GENERAL DIRECTORATE OF AGRICULTURE

ប្រចាំ (AT) :..............................

លេខ (No) :..............................

លេខកូដស្នើសុំ (APPYING CODE No) ......

កំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ

(REPORT OF PLANT QUARANTINE INSPECTION OF EXPORT CONSIGNMENT)

កាលបរិច្ឆេទ និងម៉ោងត្រួតពិនិត្យ (DATE & TIME OF INSPECTION) :..............................

នាម និងគោត្តនាមភ្នាក់ងារត្រួតពិនិត្យ (INSPECTORS'S NAMES) :..............................

នាម និងគោត្តនាម និងមុខងារអ្នកចូលរួម (NAME & FUNCTION OF PARTICIPANTS) :..............................

១. លទ្ធផលនៃការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង (RESULT OF IN PLACE INSPECTION):

a. ការវេចខ្ចប់ត្រឹមត្រូវ (PROPER PACKAGED)	☐	b. ការវេចខ្ចប់មិនត្រឹមត្រូវ/បរិយាយ (UNPROPER PACKAGED/ DESCRIPTION)	☐	:..............................
c. អវត្តមានសមាសភាពចង្រៃរស់ (NO LIVING PEST)	☐	d. វត្តមានសមាសភាពចង្រៃរស់ (DETECTION OF LIVING PEST)	☐	:..............................
e. អវត្តមានសមាសភាពចង្រៃងាប់ (NO DEAD PEST)	☐	f. វត្តមានសមាសភាពចង្រៃងាប់/បរិយាយ (DETECTION OF DEAD PEST/ DESCRIPTION)	☐	:..............................
g. គ្មានសញ្ញាសង្ស័យនៃការរាតត្បាត (NO SUSPECTED SYMPTOM)	☐	h. មានសញ្ញាសង្ស័យនៃការរាតត្បាត/បរិយាយ (SUSPECTED SYMPTOM/DESCRIPTION)	☐	:..............................
i. ការសន្និដ្ឋានលើការត្រួតពិនិត្យផ្ទាល់ (CONCLUSION OF IN PLACE INSPECTION)		....		

២. លទ្ធផលនៃការវិភាគនៅមន្ទីរពិសោធន៍រោគវិនិច្ឆ័យ (RESULT OFDIAGNOSIS'S LAB TEST):

a. ចំនួនសំណាកដែលត្រូវវិភាគ :.......... (No. OF SAMPLES)	b. នាម និងគោត្តនាមមន្ត្រីទទួលខុសត្រូវ (NAME OF RESPONSIBLE OFFICER) :..............................	
c .កាលបរិច្ឆេទចាប់ផ្តើម :.............. (STARTED DATE)	d .កាលបរិច្ឆេទបញ្ចប់ :.............. (COMPLETED DATE)	e .លទ្ធផល :.............................. (RESULTED)

៣. ការសម្រេចរបស់សមត្ថកិច្ច ភ.គ.អ (DECISION OF PQ AUTHORITY):

a. អនុញ្ញាតជម្រះទំនិញ (CLERANCE) ☐	b. កែសម្រួលការវេចខ្ចប់ (RE PACKAGE) ☐	c. ធូមទកម្ម (FUMIGATION) ☐	d. បាញ់ថ្នាំផ្ទៃខាងក្រៅ (DISINFESTATION) ☐
e. ប្តូរគោលដៅប្រើប្រាស់ទំនិញ (CHANCE OF USE'S PURPOSE) ☐ :..............................		f. វិធាន ភ.គ.អ ដទៃទៀត (OTHER PQ TREATMENT) ☐ :..............................	
g. ការបញ្ជាក់របស់ ភ.គ.អ បន្ទាប់ពីចំណាត់វិធាន ភ.គ.អ (PQ CERTIFY AFTER PQ TREATENTED) :..............................			

៤. ការចុះហត្ថលេខាឯកភាព និងបញ្ចប់របាយការណ៍ (APPROVED AND COMPLETED SIGNATURES)

ម៉ោង/កាលបរិច្ឆេទបញ្ចប់របាយការណ៍ (TIME & DATE OF COMPLETION REPORT) ....

អ្នកធ្វើកំណត់ហេតុ (REPORTER) ....

ម្ចាស់ទំនិញ ឬ តំណាង (GOOOS OWNER/REPRESENTATIVE) ....

ការសម្រេចរបស់សមត្ថកិច្ច ភ.គ.អ (DECISION OF PQ AUTHORITY) ....

ឧបសម្ព័ន្ធ ៨ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

KINGDOM OF CAMBODIA
Nation Religion King

GENERAL DIRECTORATE OF AGRICULTURE
PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

PHYTOSANITARY CERTIFICATE

No.NNN/YY

From: Plant Protection Organization of Cambodia		To: Plant Protection Organization(s) of........................
I. DESCRIPTION OF CONSIGNMENT		
Name and address of exporter		Declared name and address of consignee
....		....
Number and description of packages		Distinguishing marks
....		....
Place of Origin	Declared means of conveyance	Declared point of entry
....	....	....
Name of produce and quantity		Botanical name of plants
ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL		ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL NNN/YY ORIGINAL

This is to certify that the plant and plant products or other regulated articles described herein have been inspected and /or tested according to appropriate official procedures and are considered to be free from the quarantine pests specified by the importing contracting party and to conform with the current phytosanitary requirements of the importing contracting party, including those for regulated non-quarantine pests.

II. ADDITIONAL DECLARATION

....

III. DISINFESTATION AND / OR DISINFECTION TREATMENT

Treatment Date:	Treatment: ....
Chemical (Active ingredients):	Duration & Temperature :..
Concentration:	Additional information: ....

Date Inspected :......................... Place of Issue: Phnom Penh Date Issued :.............. ....

(Signature & Stamp of GDA Director General)	(Signature of PP-SPSD Director)
GENERAL DIRECTOETAE OF AGRICALTURE	PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

SAMPLE

ឧបសម្ពន្ធ ៩ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

KINGDOM OF CAMBODIA
Nation Religion King

GENERAL DIRECTORATE OF AGRICULTURE
PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

PHYTOSANITARY CERTIFICATE FOR RE EXPORT No.NNN/YY

From: Plant Protection Organization of Cambodia		To: Plant Protection Organization(s) of........................
I. DESCRIPTION OF CONSIGNMENT		
Name and address of exporter		Declared name and address of consignee
Number and description of packages		Distinguishing marks
Place of Origin	Declared means of conveyance	Declared point of entry
Name of produce and quantity		Botanical name of plants

This is to certify that the plants, plant products or other regulated articles described above were imported into Cambodia from ____________ covered by Phytosanitary certificate No. ________,*original ☐ certified true copy ☐ of which is attached to this certificate; that they are packed ☐ repacked ☐ in original ☐ *new ☐ containers, that based on the original phytosanitary certificate ☐ and additional inspection ☐, they are considered to conform with the current phytosanitary requirements of the importing contracting party, and that during storage in Cambodia, the consignment has not been subjected to the risk of infestation or infection.

II. ADDITIONAL DECLARATION

....

III. DISINFESTATION AND / OR DISINFECTION TREATMENT

Treatment Date:	Treatment: ....
Chemical (Active ingredients):	Duration & Temperature: ....
Concentration:	Additional information: ....

Date Inspected:......................... Place of Issue: Phnom Penh Date Issued :........... ....

(Signature & Stamp of GDA Director General)	(Signature of PP-SPSD Director)
GENERAL DIRECTOETAE OF AGRICALTURE	PLANT PROTECTION SANITARY AND PHYTOSANITARY DEPARTMENT

ឧបសម្ព័ន្ធ ៧ប្រ នៃប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ (No)..................

ពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញឆ្លងកាត់
(Application for Plant Quarantine Inspection of Transit Consignment)

នាម និងគោត្តនាមអ្នកសុំ (APPLICANT'S NAME) ....

ឈ្មោះក្រុមហ៊ុន (COMPANY NAME) ....

អាសយដ្ឋានក្រុមហ៊ុន និងទូរស័ព្ទទំនាក់ទំនង (COMPANY ADDRESS & CONTACT PHONE'S NUMBER) ....

សម្រាប់សមត្ថកិច្ច ភ.គ.អ. (FOR PQ AUTHORITY)
- លេខកូដស្នើសុំ:..............
- ចំណាត់ការ:
....
....
....

សូមគោរពជូន
សមត្ថកិច្ចភូតគាមអនាម័យប្រចាំ ....
TO THE PLANT QUARANTINE AUTHORITY OF

កម្មវត្ថុ: (Subject)	សុំការត្រួតពិនិត្យឆ្លងកាត់: .... (APPLY FOR TRANSIT INSPECTION OF).....................................

ឯកសារជូនភ្ជាប់ (ATTACHED DOCUMENTS):

ឯកសារ	☐	សំគាល់ (NOTE):
1. វិញ្ញាបនបត្រភូតគាមអនាម័យ ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចេញ (PHYTOSANITARY CERTIFICATE ISSUED BY PQ AUTHORITY OF EXPORT COUNTRY)	☐	1. ចាំបាច់ត្រូវតែមាន (NESSESSARY DOCUMENT)
2. វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចេញបន្ត (PHYTOSANITARY CERTIFICATE FOR RE EXPORT ISSUED BY PQ AUTHORITY OF RE EXPORT COUNTRY)	☐	2 ប្រសិនបើនាំចេញពីប្រទេសទី ២ (IN CASE OF EXPORT FROM 2nd COUNTRY)
3. លិខិតអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលចេញដោយ ប្រទេសនាំចូល (IMPORT CERTIFICATE/PERMIT FOR PLANT QUARANTINE MATERIALS, ISSUED BY IMPORTING COUNTRY)	☐	3. សម្រាប់ទំនិញដែលមានហានិភ័យខ្ពស់ (FOR PQ HIGH RISK GOODS)
4. ឯកសារផ្សេងទៀតតាមការតម្រូវនៃឯកសារជូនភ្ជាប់ទី ៣ ដែលចេញដោយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេសនាំចេញ និង/ឬ នាំចេញបន្ត (OTHER DOCUMENTS AS REQUIRED BY 2nd ATTACHED DOCUMENT ISSUED BY EXPORT AND/OR RE EXPORT COUNTRIES)	☐	4. សម្រាប់ទំនិញដែលមានហានិភ័យខ្ពស់ (FOR PQ HIGH RISK GOODS)
5. វិញ្ញាបនបត្រធូបទេកម្ម (FUMIGATION/DISINFESTATION CERTIFICATE)	☐	5. ប្រសិនបើមាន (IF AVAILABLE)
6. វិក្កយបត្រទំនិញ (INVOICE) និងបញ្ជីវេចខ្ចប់ (& PACKING LIST)	☐	6. ចាំបាច់ត្រូវតែមាន (NESSASSARY DOCUMENT)
7. បញ្ជីផ្ទុកទំនិញ (BILL OF LADING)	☐	7. ចាំបាច់ត្រូវតែមាន (NESSASSARY DOCUMENT)

សំគាល់ (NOTE): សូមគូស ☑ចំពោះឯកសារជូនភ្ជាប់ដែលមាន (PLEASE MAKE A NOTE ☑ FOR AVAILABLE ATTACHED DOCUMENTS)

ការពិពណ៌នាអំពីមុខទំនិញ (DESCRIPTION OF GOODS):

១.ច្រកចូល និងច្រកចេញ (1. ENTRY AND EXIT POINT)	....	២.ផ្លូវបន្តដឹកទំនិញ (2 TRANSPORT'S WAY OF GOODS)	....
៣.រយៈពេលឆ្លងកាត់ប្រមាណជា (3.ESTIMATED OF TRANSIT PERIOD)	....	៤.ច្រក និងប្រទេសគោលដៅ (4. ENTRY AND COUNTRY DESTINATION)	....

សេចក្តីថ្លែងរបស់អ្នកស្នើសុំ (APPLICANT'S STATEMENT)

នាងខ្ញុំ/ខ្ញុំបាទ/ក្រុមហ៊ុនយើងខ្ញុំ សូមប្រកាសថា ឯកសារជូនភ្ជាប់ និងព័ត៌មានទាំងអស់ខាងលើ ពិតជាត្រឹមត្រូវមិនមានការក្លែងបន្លំ និងគោរពតាមវិធានភូតគាមអនាម័យ។ (I WOULD LIKE TO CERTIFY THAT ALL ATTACHED DOCUMENTS AND INFORMATIONS DECLARED ABOVE ARE TRUE, AND RESPECT TO ALL PHYTOSANITARY TREATMENT AS REQUIRED)

ច្រកទ្វារ, កាលបរិច្ឆេទ (CHECK POINT, DATE) .... ហត្ថលេខា និង/ឬត្រាក្រុមហ៊ុនដែលស្នើសុំ (SIGNATURE AND/OR STAMP OF COMPANY) ....

ឧបសម្ព័ន្ធ ១១ នៃប្រកាសលេខ ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ Nation Religion King

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MINISTRY OF AGRICULTURE FORESTRY AND FISHERIES

សមត្ថកិច្ចភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
PLANT QUARANTINE AUTHORITY OF
GENERAL DIRECTORATE OF AGRICULTURE

ប្រចាំ (AT) :...............

លេខ (No): ....
លេខកូដស្នើសុំ (APPYING CODE No). ....

កំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់
(REPORT OF PLANT QUARANTINE INSPECTION OF TRANSIT CONSIGNMENT)

I. ការត្រួតពិនិត្យផ្ទាល់នៅច្រកទ្វារចូល (THE ENTRY PQ INSPECTION): ....

កាលបរិច្ឆេទ និងម៉ោងត្រួតពិនិត្យ (DATE & TIME OF INSPECTION) :..............................

នាម និងគោត្តនាមភ្នាក់ងារត្រួតពិនិត្យ (INSPECTORS'S NAMES) :..............................

នាម និងគោត្តនាម និងមុខងារអ្នកចូលរួម (NAME & FUNCTION OF PARTICIPANTS) :..............................
....

កម្មវត្ថុត្រួតពិនិត្យ (INSPECTION SUBJECT)

* ប្រភេទ និងបរិមាណទំនិញ (NAME & QUANTITY OF GOODS) :..............................
* មធ្យោបាយដឹកជញ្ជូន (MEAN OF CONVEYANCE) :..............................

១. លទ្ធផលនៃការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងលើផ្ទៃខាងក្រៅនៃបន្ទុកទំនិញ (RESULT OF IN PLACE INSPECTION):

a. បន្ទុកទំនិញមានភាពមាំ (GARGO IN GOOD CONDITION) ☐	b. បន្ទុកទំនិញមិនមានភាពមាំ (GARGO IN BAD CONDITION) ☐	:..............................
c. អវត្តមានសមាសភាពចង្រៃរស់ (NO LIVING PEST) ☐	d. វត្តមានសមាសភាពចង្រៃរស់ (DETECTION OF LIVING PEST) ☐	:..............................
e. អវត្តមានសមាសភាពចង្រៃងាប់ (NO DEAD PEST) ☐	f. វត្តមានសមាសភាពចង្រៃងាប់/បរិយាយ (DETECTION OF DEAD PEST/ DESCRIPTION) ☐	:..............................
g. គ្មានសញ្ញាសង្ស័យនៃការរាតត្បាត (NO SUSPECTED SYMPTOM) ☐	h. មានសញ្ញាសង្ស័យនៃការរាតត្បាត/បរិយាយ (SUSPECTED SYMPTOM/DESCRIPTION) ☐	:..............................
